# លូកា ១៨

អ្នកនិពន្ធ រ៉ូហ្វ លេភិឡារ

**១៨:១-៨ ចៅក្រម និងស្ត្រីមេម៉ាយ**

រឿងប្រៀបប្រដូចនេះគឺពិតជាផ្នែកចុងក្រោយនៃសេចក្តីបង្រៀនអំពីអនាគតនៅក្នុង ១៧:២០-១៨:៨។ ពាក្យប្រៀបប្រដូចនេះបង្រៀនយើងឱ្យតស៊ូនៅក្នុងសេចក្តីអធិស្ឋាន។ យោងតាមច្បាប់ក្នុងព្រះគម្ពីរសញ្ញាចាស់ចៅក្រមត្រូវតែកោតខ្លាចព្រះជាម្ចាស់ហើយការពារអ្នកដែលត្រូវគេជិះជាន់។ ស្ត្រីមេម៉ាយគឺជាមនុស្សដែលត្រូវគេជិះជាន់ ពីព្រោះមិន មាននរណាម្នាក់គាំទ្រនាងឡើង។ នៅក្នុងរឿងនេះ ស្ត្រីម្នាក់នេះប្រហែលជាកំពុងប្តឹងដល់ចៅក្រមអំពីករណីប្រាក់កាសហើយលោកចៅក្រោមបានបដិសេធមិនស្តាប់គាត់ដោយព្រោះគាត់ចង់សំណូក ប៉ុន្តែនាងជាជនក្រីក្រលំបាកខ្លាំងក្នុងការផ្តល់សំណូក ដូច្នេះមានតែការរំអុកទេ ដែលជាវិធីតែមួយគត់របស់នាង។ ព្រះយេស៊ូវមានបន្ទូលថា ព្រះជាម្ចាស់គឺមានភាពខុសគ្នាទៅនឹងចៅក្រមទុច្ចរិតនេះ។ សូម្បីតែចៅក្រមម្នាក់ ដែលមិនគោរពច្បាប់របស់ព្រះ ហើយអាចមនុស្សម្នាក់សម្រេចធ្វើអ្វីមួយ ដោយការរំអុកឥតឈប់ឈររបស់ស្ត្រីមេម៉ាយម្នាក់ បើអញ្ចឹង ព្រះនឹងរឹតតែរកយុត្តិធម៌អោយប្រជាជនរបស់ទ្រង់ នៅពេលពួកគេស្រែកអង្វរព្រះអង្គ (ពីព្រោះព្រះជាម្ចាស់ល្អជាងចៅក្រមនេះ)។

នៅក្នុង ខ.៧ «ពួករើសតាំងរបស់ទ្រង់» គឺជាអស់អ្នក ដែលបានឮដំណឹងល្អហើយទទួលជឿព្រះយេស៊ូវ។ នៅអត្ថបទនេះ ព្រះយេស៊ូវបង្រៀនអំពីពួកគេត្រូវបានទទួលរងការបៀតបៀន ហើយពួកគេទន្ទឹងរងចាំព្រះអង្គប្រទានយុត្តិធម៌ដល់ពួកគេ។

«នោះតើទ្រង់មិនសងសឹកជំនួសគេដែរទេឬអី » (ខ.៧) [«ព្រះអង្គគ្រាន់តែបង្អង់ប៉ុណ្ណោះ» ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន(គខប Khmer Standard Version)]។ តាមពិត អត្ថបទភាសាក្រិកដើមគឺជាសំនួរ ហើយសំនួរនេះបង្ហាញថា តាមទស្សននិងពិសោធន៍របស់យើង យើងប្រហែលជាគិតថា ព្រះអង្គបង្អង់ក្នុងការបង្ហាញយុត្តិធម៌និងឆ្លើយសេចក្តីអធិស្ឋានរបស់យើង ប៉ុន្តែ «ព្រះអង្គនឹងរកយុត្តិធម៌អោយពួកគេជាប្រញាប់មិនខាន»។ ដូច្នេះ យើងត្រូវទន្ទឹងរងចាំ។ សំនួរសំខាន់មិនមែនសួរថា «តើព្រះអង្គនឹងឆ្លើយសេចក្តីអធិស្ឋានរបស់យើងឬទេ?» ប៉ុន្តែ «កាលណាកូនមនុស្សនឹងមក តើនឹងឃើញមានសេចក្តីជំនឿនៅផែនដីដែរឬដូចម្តេច?»

យើងត្រូវការស្តាប់ឮការបង្រៀននេះ ពីព្រោះភាពទន់ខ្សោយរបស់យើងធ្វើអោយយើងរសាយចិត្ត ហើយឈប់ជឿ ។ ទស្សនវិស័យរបស់យើងនៅមានកម្រិតនិងនិមិត្តរបស់យើងមានភាពមិនច្បាស់លាស់។ ព្រះគម្ពីរបន្តរំលឹកយើងថា ព្រះជាម្ចាស់ពិតជាកាន់ខាងយើងនៅក្នុងព្រះយេស៊ូវ (សូមមើលរ៉ូម ៨: ៣១-៣៣)។ យើងត្រូវការការរំលឹកខ្ជាប់ខ្ជួននេះអំពីសេចក្តីស្រឡាញ់របស់ព្រះចំពោះយើងនិងអំណាចយ៉ាងខ្លាំងរបស់ទ្រង់ពេលយើងតយុទ្ធជាមួយនឹងការសង្ស័យរបស់យើង។ ឥឡូវនេះ យើងជាកម្មសិទ្ធិរបស់ទ្រង់ហើយ។ ព្រះអង្គសព្វព្រះទ័យក្នុងការថែទាំនិងការពារយើងខ្លាំងណាស់។

## ១៨:៩-១៩:១០ ទំហំនៃសេចក្តីសង្គ្រោះ

ផ្ទៃរឿងទូទៅនៅក្នុង អត្ថបទនេះគឺជាការប្រទានសេចក្តីសង្គ្រោះដល់មនុស្ស ដែលជាធម្មតាត្រូវបានចាត់ទុកថាជាមនុស្សមិនសមស្របដើម្បីទទួលបានសេចក្តីសង្គ្រោះ។

**១៨:៩-១៤ ពួកផារីស៊ីនិងអ្នកទារពន្ធ**

មនុស្សបានគិតថា ពួកផារិស៊ីជាមនុស្សសុចរិតជាងគេនៅក្នុងសង្គមយូដា ប៉ុន្តែអ្នកទារពន្ធគឺជា មនុស្សគួរឱ្យស្អប់បំផុត ហើយជាធម្មតាមនុស្សចាត់ទុកថាពួកអ្នកទារពន្ធជាជនក្បត់ដែលបានបម្រើចក្រភពរ៉ូម៉ាំង។ រឿងប្រៀបប្រដូចនេះចង់បង្រៀនអំពីការអធិស្ឋាន ដូចជារឿងប្រៀបប្រដូចមុននេះ (១៨:១-៨) ផងដែរ ប៉ុន្តែអត្ថបទនេះពិតជាបង្រៀនអំពីប្រធានបទធំជាងមួយ។ ការអធិស្ឋានទាំងពីរបានពិពណ៌នាអំពីមនុស្សពីរប្រភេទ។ ពួកផារិស៊ីជាមនុស្សម្នាក់គោរពព្រះជាម្ចាស់ រស់មានភាពស្មោះត្រង់និងទៀងត្រង់។ គាត់បានធ្វើច្រើនជាងសេចក្តីបង្គាប់របស់ក្រិត្យវិន័យទៅទៀត។ ឧទាហរណ៍ គាត់បានតមអាហារពីរដងក្នុងមួយសប្តាហ៍ នៅថ្ងៃច័ន្ទនិងថ្ងៃព្រហស្បតិ៍ នៅពេលក្រិត្យវិន័យតម្រូវឱ្យមនុស្សតមអាហារតែម្តងប៉ុណ្ណោះក្នុងមួយឆ្នាំ នៅថ្ងៃធួននឹងបាប (ថ្ងៃអោយបានធួននឹងបាប ថ្ងៃបុណ្យរំដោះបាប) ហើយគាត់បានថ្វាយដល់មួយភាគដប់ពីប្រាក់ចំណូលរបស់គាត់ទាំងអស់ ដែលលើសពីចំនួនតម្រូវ។ ប៉ុន្តែគាត់បានក្រោកឈរឡើងអធិស្ឋាននៅក្នុងកន្លែងដ៏លេចធ្លោមួយគាត់បានសរសើរខ្លួនឯងថាគាត់ជាមនុស្សគោរពព្រះជាម្ចាស់ (សេចក្តីអធិស្ឋាននិយាយតែអំពី «ខ្ញុំ») គាត់បានមើលងាយអ្នកជិតខាងរបស់ខ្លួន ហើយការអធិស្ឋានរបស់គាត់ទៅព្រះជាម្ចាស់ប្រៀបដូចជាគាត់កំពុងនិយាយទៅកាន់ព្រះជាម្ចាស់ថា គាត់មិនត្រូវការអ្វីសោះឡើយ។

ផ្ទុយពីអ្នកផារីស៊ី អ្នកទារពន្ធបានឈរនៅឆ្ងាយពីទីបរិសុទ្ធនៅក្នុងព្រះវិហារ។ គាត់មិនហ៊ានងើបភ្នែករបស់គាត់ឬដៃរបស់គាត់ទៅព្រះ ទេ ប៉ុន្តែគាត់បានសារភាពអំពើបាបរបស់គាត់ ហើយបានទូលសូមសេចក្តីមេត្តាករុណាពីព្រះវិញ។ ព្រះយេស៊ូវបង្រៀនថា ព្រះជាម្ចាស់បានរាប់អ្នកទារពន្ធជាសុចរិត («រាប់ជាសុចរិត» គឺជាការបកប្រែល្អជាង «ប្រោសអោយបានសុចរិត»)។ លើសពីនេះទៅទៀត ព្រះយេស៊ូវបង្រៀនថា ព្រះជាម្ចាស់មិនរាប់បុរសខាងគណៈផារិស៊ីជាសុចរិតទេ។ រឿងប្រៀបប្រដូចនេះបង្ហាញថា ព្រះជាម្ចាស់សង្គ្រោះមនុស្សដែលអ្នកដទៃបដិសេធ។ ព្រះអង្គតែងតែទទួលយកមនុស្សទុច្ចរិត នៅពេលបន្ទាបខ្លួនចំពោះហើយទូលអង្វរដល់ព្រះអង្គ ប៉ុន្តែព្រះអង្គមិនស្តាប់អស់អ្នកណា ដែលមានអំនួតនៅក្នុងការប្រព្រឹត្តិតាម ដែលធ្វើអោយពួកគេគិតថា ពួកគេមានគ្រប់គ្រាន់សំរាប់ខ្លួនឯងហើយ។

មានពីរគ្រោះថ្នាក់ នៅពេលយើងអានរឿងប្រៀបប្រដូចនេះ។ ទីមួយគឺថា យើងបញ្ឆោតខ្លួនឯងដោយគិតថា យើងគឺដូចជាអ្នកទារពន្ធ នៅពេលយើងដូចជាផារិស៊ីនោះ។ ទីពីរ យើងឃើញថា បុរសផារិស៊ីនោះមាន

អំនួត ប៉ុន្តែយើងនៅតែគិតអំពីអ្នកណាបានសង្គ្រោះឬអត់តាមគំនិតលោកិយផងដែរអនុវត្តយោបល់របស់លោកិយអំពី អ្នកណាបានសង្គ្រោះ ឬមិនបានសង្គ្រោះ។

(១) *យើងបញ្ឆោតខ្លួន* ។ ខ្ញុំនៅចាំថា ខ្ញុំបានឮគ្រូបង្រៀននៅសាលាថ្ងៃអាទិត្យម្នាក់ ដែលបានបង្រៀនរឿងប្រៀបប្រដូចនេះ ហើយបន្ទាប់មកបានបញ្ចប់មេរៀនដោយអធិស្ឋានថា «សូមអរគុណព្រះអង្គ ពីព្រោះយើងមិនដូចជាពួកផារិស៊ីនោះ»។ នាងមិនបានដឹងថា ការអធិស្ឋានដូចនេះគឺនាង ពិតជាដូចបុរសផារិស៊ីដែរនោះទេ។

ប្រសិនបើខ្ញុំសួរអ្នក «តើអ្នកដូចជាបុរសផារិស៊ី ឬដូចជាអ្នកទារពន្ធ?» តើអ្នកឆ្លើយយ៉ាងម៉េច? ប្រសិនបើអ្នកឆ្លើយថា «ខ្ញុំដូចជាអ្នកទារពន្ធ» ខ្ញុំសួរវិញ «ហេតុអ្វីបានជាអ្នកឆ្លើយដូច្នោះ?» តើដោយសារតែអ្នកគិតថា អ្នកមិនដូចពួកផារិស៊ីនោះទេ តែល្អប្រសើរជាងគាត់ឬ? បើដូច្នោះមែន នោះអ្នកកំពុងតែដូចជាបុរសផារីស៊ីហើយ។ បើអញ្ចឹង អ្នកកំពុងបញ្ឆោតខ្លួនឯងហើយ។

ភាពខុសគ្នារវាងបុរសផារីស៊ីនិងអ្នកទារពន្ធនេះគឺថា បុរសផារិស៊ីប្រៀបធៀបខ្លួនឯងជាមួយនឹងអ្នកដទៃហើយបានគិតថា គាត់ល្អប្រសើរជាងគេ។ អ្នកទារពន្ធនេះមិនបានប្រៀបធៀបខ្លួនឯងជាមួយនឹងនរណាម្នាក់ទៀតទេ ហើយគ្រាន់តែបានសារភាពអំពើបាបរបស់ខ្លួននិងសុំសេចក្តីមេត្តាករុណាពីព្រះប៉ុណ្ណោះ។

(២) *តាមគំនិតលោកិយ។ នៅ* ពេលព្រះយេស៊ូវយាងមកវិនិច្ឆ័យទោសលោកិយនេះ បើសិនជាទ្រង់បានសួរអ្នក «ហេតុអ្វីបានជាអ្នកគួរតែបានចូលស្ថានសួគ៌?» តើអ្នកនឹងឆ្លើយយ៉ាងម៉េច?

ប្រសិនបើអ្នកឆ្លើយថា អ្នកគួរតែចូលទៅក្នុងស្ថានសួគ៌ ដោយព្រោះអ្នកបានប្រព្រឹត្តល្អហើយបានបម្រើព្រះអង្គនោះអ្នកដូចជាបុរសផារិស៊ី ហើយព្រះអង្គក៏នឹងបដិសេធអ្នកផងដែរ។ បើសិនអ្នកឆ្លើយថា អ្នកមិនសមអោយព្រះទទួលយកអ្នក ពីព្រោះអ្នកពោរពេញដោយអំពើបាប ប៉ុន្តែ អ្នកពឹងផ្អែកលើសេចក្តីមេត្តាករុណារបស់ទ្រង់ ដែលបានបង្ហាញតាមរយៈព្រះយេស៊ូវ នោះអ្នកដូចជាអ្នកទារពន្ធ ហើយព្រះនឹងទទួលយកអ្នក ដូចជាទ្រង់បានទទួលយកអ្នកទារពន្ធនោះផងដែរ។

ប្រជាជនខ្មែរជាញឹកញាប់និយាយថា «សាសនាទាំងអស់សុទ្ធតែដូចគ្នា គឺសាសនាទាំងអស់បង្រៀនមនុស្សឱ្យល្អ »។ យោងតាមគំនិតនេះ ព្រះយេស៊ូវគ្រាន់តែជាគ្រូបង្រៀនម្នាក់ ដែលបង្រៀនមនុស្សឱ្យបានធ្វើល្អប៉ុណ្ណោះ។ រឿងប្រៀបប្រដូចនេះបង្ហាញថា គំនិតនេះគឺជាការយល់ខុសទាំងស្រុងអំពីព្រះយេស៊ូវ។

ដូច្នេះ រឿងប្រៀបប្រដូចនេះពន្យល់អំពីដំណឹងល្អពីព្រោះដំណឹងល្អគឺថា ព្រះជាម្ចាស់សង្គ្រោះមនុស្សមានបាប និងរឿងប្រៀបប្រដូចនេះបង្ហាញពីការឆ្លើយតបត្រឹមត្រូវចំពោះដំណឹងល្អ បន្ទាបខ្លួន យើង មិនអោយប្រៀបធៀបខ្លួនយើងជាមួយអ្នកដទៃ សារភាពអំពើបាបរបស់យើងហើយទូលសូមសេចក្តីមេត្តាករុណាតាមរយៈព្រះយេស៊ូវវិញ។

**ព្រះយេស៊ូវប្រទានពរអោយក្មេងៗ (១៨:១៥-១៧)**

ការបង្រៀនរបស់ព្រះយេស៊ូវអំពីក្មេងៗគឺជាមេរៀនទីពីរ ដែលលោកលូកាបានបង្ហាញអំពីឥរិយាបថ ដែលយើងត្រូវមាន ដើម្បីទទួលបានព្រះគុណរបស់ព្រះ។ ព្រះយេស៊ូវមិនមានបន្ទូលថា យើងត្រូវតែមានអាយុក្មេង ដើម្បីចូលទៅក្នុងនគរព្រះទេ ប៉ុន្តែយើងត្រូវមានអាកប្បកិរិយាដូចក្មេង ដូចជាការទុកចិត្តនិងភាពពឹងពាក់ទៅលើគេ។ យើងត្រូវទុកចិត្តព្រះគ្រីស្ទនិងពឹងពាក់ទៅលើព្រះអង្គ។

**អ្នកមានម្នាក់ចង់បានជីវិតអស់កល្បជានិច្ច (១៨:១៨-៣០)**

អត្ថបទនេះបន្តបង្រៀនអំពីឥរិយាបថត្រឹមត្រូវ ដែលព្រះទទួលយក។ សូមកំណត់ថា «អោយបានជីវិតរស់អស់កល្បជានិច្ច» (ខ.១៨) «ចូលទៅក្នុងនគរព្រះ» (ខ.២៤-២៥) «បានសង្គ្រោះ» (ខ.២៦) គឺជាសទិសន័យនៅក្នុងរឿងនេះ។ ចម្លើយរបស់ព្រះយេស៊ូវប្រហែលជាធ្វើអោយយើងច្រឡំ ពីព្រោះហាក់ដូចជាព្រះគ្រីស្ទបដិសេធថា ទ្រង់គឺជាព្រះ។ ប៉ុន្តែព្រះយេស៊ូវមិនបដិសេធថា ទ្រង់គឺជាព្រះទេ ប៉ុន្តែគ្រាន់តែចង់ជៀសវាងពីការបញ្ឆោរ។ ព្រះយេស៊ូវបានឆ្លើយតាមទំនៀមទម្លាប់របស់ជនជាតិយូដា គឺទ្រង់ថា យើងត្រូវប្រតិបត្តិតាមបទបញ្ញត្តរបស់ព្រះអង្គ។ នៅពេលអ្នកមាននេះបានអះអាងថា គាត់ប្រតិបត្តិតាមបទបញ្ញត្ត ហើយ ព្រះយេស៊ូវឆ្លើយថា មានកិច្ចការមួយទៀតដែលគាត់ត្រូវធ្វើ (ខ.២១)។ អ្នកមានមិនព្រមធ្វើកិច្ចការ ដែលព្រះគ្រីស្ទបង្គាប់ទេ ហើយនេះបង្ហាញថា គាត់ពិតជាមិនស្រឡាញ់អ្នកជិតខាងដូចជាខ្លួនឯង ហើយទ្រព្យសម្បត្តិរបស់គាត់សំខាន់ជាងព្រះជាម្ចាស់ (សូមមើល លូកា១០:២៧)។ គាត់បានស្តាប់បង្គាប់ខាងក្រៅ តែចិត្តរបស់គាត់មិនផ្តាប់ព្រះទ័យរបស់ព្រះឡើយ។  ការឆ្លើយតបរបស់ព្រះយេស៊ូវបង្ហាញថា អ្នកមានពិបាកនឹងទទួលជីវិតអស់កល្បជានិច្ចណាស់។ នៅក្នុងលោកិយនេះ យើងមើលឃើញថា  មនុស្សខិតខំសង្វាតចង់បានទ្រព្យសម្បត្តិខ្លាំងជាទទួលបានជីវិតអស់កល្បជានិច្ច។ ពួកសិស្សស្រឡាំងកាំងទាំងអស់គ្នាដោយសារការបង្រៀនរបស់ទ្រង់ (ខ.២៦)។ ប៉ុន្តែ ថ្វីបើមនុស្សមិនមានសមត្ថភាពឈ្នះលើនិស្ស័យបាបនៅក្នុងចិត្តក៏ដោយ ក៏ព្រះជាម្ចាស់មានព្រះចេស្តាផ្លាស់ប្រែចិត្តរបស់យើង ដើម្បីអោយយើងស្តាប់តាមទ្រង់បាន។

យើងត្រូវចាំបរិបទនៃការឆ្លើយតបរបស់ព្រះយេស៊ូវ «ការដែលមនុស្សធ្វើមិនកើត នោះព្រះទ្រង់អាចនឹងធ្វើកើតទាំងអស់» (ខ.២៧)។ ជាញឹកញាប់គេដកស្រង់ខនេះដោយមិនគិតអំពីបរិបទរបស់វាទេ។ មនុស្សប្រហែលគិតថា «ខ្ញុំចង់មានផ្ទះស្អាតមួយ ប៉ុន្តែខ្ញុំមិនមានលុយ ប៉ុន្តែព្រះយេស៊ូវមានបន្ទូលថា ការដែលមនុស្សធ្វើមិនកើត នោះព្រះទ្រង់អាចនឹងធ្វើកើតទាំងអស់ ដូច្នេះបើខ្ញុំជឿលើព្រះជាម្ចាស់ ព្រះអង្គនឹងប្រទានផ្ទះស្អាតអោយខ្ញុំ ពីព្រោះព្រះទ្រង់អាចនឹងធ្វើកើតទាំងអស់»។ ការយកខនេះ មកអនុវត្តបែបនេះគឺជាការអនុវត្តផ្ទុយពីអ្វី ដែលព្រះយេស៊ូវបានបង្រៀនហើយ។ អ្វីដែលព្រះយេស៊ូវកំពុងតែបង្រៀនគឺថា ព្រះអង្គអាចនឹងសង្គ្រោះមនុស្សបាន ទ្រង់អាចនឹងផ្លាស់ប្រែចិត្តរបស់គេ ដើម្បីគេនឹងតាមអ្វីដែលទ្រង់មានបន្ទូល ហើយស្រឡាញ់ព្រះអង្គជាជាងទ្រព្យសម្បត្តិបោះបង់ទ្រព្យសម្បត្តិហើយដើរតាមព្រះយេស៊ូវវិញ។ ការឆ្លើយតបរបស់ព្រះយេស៊ូវចំពោះពេត្រុសបង្ហាញថា អស់អ្នកដែលលះបង់ចោលទាំងអស់ ហើយមកតាមព្រះអង្គ នឹងបានទទួលពរធំជាងទាំងពេលឥឡូវនេះនិងពិភពលោកថ្មី។

**ព្រះយេស៊ូវប្រកាសអំពីព្រះអង្គសោយទិវង្គត (១៨:៣១-៣៤)**

នេះជាទំនាយទីប្រាំពីរ (ដែលលូកាកត់ត្រាទុក) ដែលព្រះយេស៊ូវបានប្រកាសអំពីការរងទុក្ខនិងការសុគត របស់ទ្រង់ (៥:៣៥; ៩:២២,៤៣-៤៥; ១២:៥០; ១៣:៣២..; ១៧:២៥)។ សេចក្តីពិតនេះបង្ហាញថា ការសុគតនិងការរស់ឡើងវិញរបស់ព្រះយេស៊ូវគឺជាខ្លឹមសារនៃបេសកកម្មរបស់ទ្រង់។ ក្នុងកណ្ឌទាំងមូល ជីវិតនិងការបង្រៀនរបស់ព្រះយេស៊ូវនាំឆ្ពោះទៅការសុគតរបស់ព្រះអង្គ។ ទំនាយទាំងនេះក៏បានបង្ហាញថា ព្រះយេស៊ូវឈ្វេងយល់អំពីព្រឹត្តិការណ៍ ដែលនឹងមានកើតឡើង ការសុគតរបស់ទ្រង់មិនមែនកើតឡើងដោយចៃដន្យទេ ប៉ុន្តែកើតឡើងតាមផែនការណ៍របស់ព្រះជាម្ចាស់។ «គេនឹងបញ្ជូនលោកទៅពួកសាសន៍ដទៃ» (ខ.៣២) គឺជារបៀបមួយ ដែលគេបាននិយាយនៅក្នុងព្រះគម្ពីរសញ្ញាចាស់អំពីការទទួលទណ្ឌកម្មពីព្រះជាម្ចាស់។ ជារឿយៗ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ព្រះជាម្ចាស់បានដាក់ទោសរាស្ត្ររបស់ព្រះ ដោយបញ្ជូនគេទៅពួកសាសន៍ដទៃ ប្រយោជន៍អោយសាសន៍ដទៃនឹងសង្កត់សង្កិនពួកគេ។ ដូច្នេះ អត្ថបទនេះបង្ហាញយ៉ាងច្បាស់ថា ព្រះយេស៊ូវយល់ថា បេសកកម្មរបស់ទ្រង់គឺ ព្រះអង្គត្រូវទទួលទណ្ឌកម្មពីព្រះជាម្ចាស់ប្រយោជន៍អោយព្រះអង្គនឹងលើកលែងទោសរបស់យើង ហើយបន្ទាប់មក ព្រះយេស៊ូវនឹងរស់ឡើងវិញ ដែលជាភស្តុតាងបង្ហាញថា ព្រះយេស៊ូវពិតជាព្រះរាជបុត្រា ហើយព្រះវរបិតាបានទទួលព្រះលោហិតរបស់ព្រះយេស៊ូវជាយញ្ញបូជាឲ្យធួននឹងបាប។ ទំនាយរបស់ព្រះយេស៊ូវបង្ហាញថា ព្រះយេស៊ូវមិនគ្រាន់តែជាគ្រូបង្រៀនដ៏ល្អម្នាក់ ដែលនាំយើងប្រព្រឹត្តល្អប៉ុណ្ណោះទេ ប៉ុន្តែទ្រង់គឺជាព្រះអង្គសង្គ្រោះដោយទ្រង់បានទទួលទណ្ឌកម្មរបស់យើង។ នៅក្នុងខ.៣១ ព្រះយេស៊ូវប្រើឋានន្តរ «កូនមនុស្ស» [«បុត្រមនុស្ស» ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន (គខប Khmer Standard Version)] ហើយនេះជាឋានន្តរមកពីកណ្ឌដានីយ៉ែល ៧:១៣ ដែលសំដៅទៅលើព្រះមែស៊ី (សូមមើលមេរៀនអំពីកូនមនុស្សនៅគេហទំព័រនេះ)។

**ព្រះយេស៊ូវប្រោសមនុស្សខ្វាក់ម្នាក់អោយភ្លឺ (១៨:៣៥-៤៣)**

នៅពេលមនុស្សខ្វាក់នេះបានឮថា ព្រះយេស៊ូវយាងមកតាមផ្លូវគាត់ស្រែកឡើងថា៖ «...ព្រះវង្សហ្លួង ដាវីឌ ...» [ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន (គខប Khmer Standard Version) «...ព្រះរាជវង្សព្រះបាទដាវីឌ...»]។ មនុស្សខ្វាក់នេះគឺជាមនុស្សតែម្នាក់នៅក្នុងកណ្ឌលូកា ដែលបានប្រើឋានន្តរនេះ ដើម្បីហៅព្រះយេស៊ូវ (ព្រះយេស៊ូវផ្ទាល់បានប្រើឋានន្តរនេះនៅក្នុង ២០:៤១។ ឋានន្តរ «ព្រះវង្សហ្លួងដាវីឌ» គឺជាឋានន្តរមួយសម្រាប់ព្រះមែស៊ី ស្តេចអ៊ីស្រាអែល ហើយឋានន្តរនេះមកពីសេចក្តីសន្យារបស់ព្រះជាម្ចាស់ដល់ស្តេចដាវីឌនៅក្នុង ២ សាំយូអែលជំពូក៧។ មនុស្សខ្វាក់នេះរំអុកក្នុងការសូមពីព្រះ ដូច្នេះគាត់ជាគំរូល្អពីមនុស្ស ដែលទទួលពីព្រះនូវអ្វី ដែលគាត់បានទូលសូម ដោយព្រោះការរំអុកនិងសេចក្តីជំនឿរបស់គាត់ (សូមមើល ១៨:១-៨)។

នៅពេលព្រះយេស៊ូវមានបន្ទូលថា «សេចក្តីជំនឿអ្នកបានជួយសង្គ្រោះអ្នកហើយ» ទ្រង់មិនមានន័យថា សេចក្តីជំនឿរបស់អ្នកនេះបានបង្កើតសេចក្តីសង្គ្រោះទេ ប៉ុន្តែសេចក្តីជំនឿគឺជាមធ្យោបាយដែលគាត់បានទទួលសេចក្តីសង្គ្រោះពីព្រះអង្គ។ នៅពេលគាត់មើលឃើញវិញ គាត់ក៏តាមព្រះយេស៊ូទាំងលើកតម្កើង

សិរីរុងរឿងរបស់ព្រះជាម្ចាស់។ នេះគឺជាការឆ្លើយតបត្រឹមត្រូវទៅចំពោះអ្វី ដែលព្រះអង្គធ្វើសំរាប់យើងតាមរយៈសេចក្ដីមេត្តាករុណារបស់ទ្រង់។

## Bibliography


Barry, J. D., Heiser, M. S., Custis, M., Mangum, D., & Whitehead, M. M. (2012). *Faithlife Study Bible.* Bellingham, WA: Logos Bible Software.

Carson, D. A., France, R. T., Motyer, J. A., & Wenham, G. J. (1994). *New Bible commentary: 21st century edition (4th ed.).* Leicester, England; Downers Grove, IL: Inter-Varsity Press.

Chapell, B., & D., O. (2013). *Gospel Transformation Bible: English Standard Version.* Wheaton, IL: Crossway.

Gaebelein, F. (. (1984). *The Expositor's Bible Commentary: Matthew, Mark, Luke (Vol. 8).* Grand Rapids, MI: Zondervan Publishing House.

Keener, C. S. (1993). *The IVP Bible background commentary: New Testament.* Downers Grove, IL: InterVarsity Press.

Morris, L. (1988). *Luke: An introduction and commentary.* Nottingham, England: Inter-Varsity Press.